**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ០១៣៩ ព.ណ.ជ.ន...

ថ្ងៃសុក្រ ៧រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២៣

# សេចក្តីជូនដំណឹង

យោងតាមរបាយការណ៍កិច្ចប្រជុំអនុគណៈកម្មការវិធានដើមកំណើតទំនិញ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (SC-AROO) បានប្រព្រឹត្តឡើង នាថ្ងៃទី ២១-២៣ ខែមីនា ឆ្នាំ២០២២ និងរបាយការណ៍កិច្ចប្រជុំរដ្ឋមន្ត្រីក្រុមប្រឹក្សាអាហ្វតា (AFTA Council) លើកទី៣៥ កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការអនុវត្តនីតិវិធីប្រតិបត្តិការនៃការបញ្ជាក់ដើមកំណើត (Amended Operational Certificate Procedures-OCP) ដែលបានអនុម័តលើការកែសម្រួលសន្លឹកវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ ឌី (CO Form D) ដោយបានលុបនូវសន្លឹកកាបូន (Carbon) ក្រសួងពាណិជ្ជកម្ម មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ ឯកឧត្តម លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា តំណាងក្រសួងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស មន្ទីរពាណិជ្ជកម្មតាមបណ្តាខេត្តជាប់ព្រំដែន និងអ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ជាផលិតករ ឬអ្នកនាំចេញទាំងអស់មេត្តាជ្រាបថា៖ ក្រសួងពាណិជ្ជកម្មបានកែសម្រួលប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ លើការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ ឌី (CO Form D) ដើម្បីសម្រួលដល់ការបោះពុម្ព (Print) សន្លឹកវិញ្ញាបនបត្រទម្រង់ ឌី (CO Form D) បានរហ័សជាងមុនជូនពាណិជ្ជករ ឬអ្នកនាំចេញ។ ក្រសួងពាណិជ្ជកម្មនឹងសម្រេចដាក់ឱ្យអនុវត្តការកែសម្រួលថ្មីដោយប្តូរមកប្រើម៉ាស៊ីនព្រីនម៉ាក HP Laser វិញសម្រាប់ការបោះពុម្ពវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ ឌី (CO Form D) ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ តទៅ។

សម្រាប់ពាណិជ្ជករ ឬអ្នកនាំចេញដោយប្រើប្រាស់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញអេឡិចត្រូនិកទម្រង់ ឌី (ATIGA e-Form D) នៅតែអាចបន្តប្រើប្រាស់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញអេឡិចត្រូនិកទម្រង់ ឌី ដោយពុំតម្រូវបោះពុម្ព (Paper-Base CO Form D) នោះទេ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា តំណាងក្រសួងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស មន្ទីរពាណិជ្ជកម្មតាមបណ្តាខេត្តជាប់ព្រំដែន និងអ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ជា ផលិតករ ឬអ្នកនាំចេញទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

**សូមអរគុណ!**